# សេចក្តីប្រកាសពត៌មានរួមរវាងក្រសួងសុខាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងអង្គការសុខភាពពិភពលោក

ភ្នំពេញ,ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៩

មានពាក្យចចាមអារាមមួយចំនួនបានផ្សព្វផ្សាយចេញជាសាធារណៈថា មានប្រជាជនកម្ពុជាជាច្រើនបានឆ្លងជំងឺផ្តាសាយថ្មីរាតត្បាតជាសកល A/H1N1 បន្ទាប់ពីពួកគេធ្វើដំណើរត្រលប់មកពីប្រទេសថៃ និងដែលមានស្លាប់ចំនួន ១ ទៅ ៦ នាក់ ។ ក្រសួងសុខាភិបាលសូមបំភ្លឺជូនដល់សាធារណជនថា ចាប់តាំងពីមានករណីទីមួយ ដែលបានរកឃើញនៅខែមិថុនា រហូតពេលនេះយើងមានចំនួនជំងឺផ្តាសាយ A/H1N1 សរុបទាំងអស់ ១៧ ករណី នៅក្នុងប្រទេសកម្ពុជា ។ ក្នុងនោះចំនួន ១៦ ករណីសុទ្ធតែបាន ធ្វើដំណើរមកពីប្រទេស ក្រៅ ឬ បានប៉ះពាល់ជាមួយ អ្នកធ្វើដំណើរដូចគ្នា ។ គ្រប់ករណីទាំងអស់ត្រូវបានដាក់ដោយឡែក ពីប្រជាជនដទៃ និងបានទទួលការព្យាបាលពួកគេ ទាំងអស់នោះបានជាសះស្បើយហើយ ។ ក្រសួងសុខាភិបាលមានប្រព័ន្ធតាមដានជំងឺឆ្លងជាស្រេចដើម្បីតាមដានរុករកករណីជំងឺផ្តាសាយ ។ ជាបន្ថែមរាល់អ្នកដំណើរដែលចូលមកពីប្រទេសក្រៅ ត្រូវបានស្នើសុំឱ្យបំពេញទំរង់ប្រកាសសុខភាព ឬ ពិនិត្យមើលសីតុណ្ហភាព ។ ក្រសួងសុខាភិបាលបានធ្វើការតាមដានយ៉ាងល្អិតល្អន់បំផុត អំពីស្ថានភាព និង មានប្រព័ន្ធទាក់ទងជាប្រចាំរវាងក្រសួងសុខាភិបាល និង មន្ទីរសុខាភិបាល គ្រប់ខេត្ត រាជធានី ដើម្បីតាមដានពីស្ថានភាពជំងឺនេះ។

## ដំបូន្មានអប់រំសុខភាពសាធារណៈ

ក្រសួងសុខាភិបាល និង អង្គការសុខភាពពិភពលោក សូមផ្តល់ដំបូន្មានដល់សាធារណៈជនថា ដើម្បីបង្ការការចំលងជំងឺផ្តាសាយថ្មី A/H1N1 សូមអនុវត្តនូវអនាម័យជាមូលដ្ឋានគ្រប់ពេលវេលាទាំងអស់ដូចខាងក្រោមនេះ :

- ខ្ទប់មាត់ ច្រមុះ ដោយក្រដាស ឬ កន្សែង នៅពេលក្អក ឬ កណ្តាស
- លាងដៃជាមួយទឹក និង សាប៊ូ ( ជាពិសេសបន្ទាប់ពីក្អក កណ្តាស និង មុនបរិភោគ)
- កុំខាកស្តោះនៅទីសាធារណៈ

រោគសញ្ញាជំងឺផ្តាសាយថ្មី A/H1N1 រួមមាន គ្រុនក្តៅលើសពី ៣៨ អង្សារសេ និង ក្អក, ហៀរសំបោរ, ឈឺក, ដកដង្ហើមហត់ និង អស់កំលាំងល្ហិតល្ហៃ ។ ជនទាំងឡាយណាមានរោគសញ្ញាដូចខាងលើគួរស្នាក់នៅផ្ទះ, ចៀសវាងកន្លែងមានមនុស្សកកកុញ ។ បច្ចុប្បន្ននេះ ពុំទាន់មានវ៉ាក់សាំង សំរាប់ចាក់បង្ការជំងឺផ្តាសាយថ្មី A/H1N1 នៅឡើយទេ ហើយករណីឈឺភាគច្រើនពុំចាំ បាច់ព្យាបាលដោយឱសថប្រឆាំងវីរុសនេះទេ ។ ការព្យាបាលផ្សេងទៀតរួមមាន ការផឹកទឹកឱ្យបានច្រើន, សំរាក និង ប្រើឱសថ ប៉ារ៉ាសេតាម៉ុល ដើម្បីបញ្ចុះកំដៅ ។

**សូមទាក់ទងទូរស័ព្ទទាន់ហេតុការណ៍លេខ: ១១៥ , ០១២ ៤៨៨ ៩៨១, ០៨៩ ៦៦៩ ៥៦៧** ។

**សំរាប់ពត៌មានបន្ថែមសូមទាក់ទង:** វេជ្ជ. សុខ ទូច : ០១២ ៨៥៦ ៨៤៨ វេជ្ជ. លី សុវ៉ាន់ : ០១២ ៨២៥ ៤២៤

**អង្គការសុខភាពពិភពលោក :** វេជ្ជ. ម៉ៃយល អូលារី : ០២៣ ២១៦ ៦១០ វេជ្ជ. អាសហ្គារី នីម៉ា : ០១២ ៤៤៣ ៨៧៧